**មុខវិជ្ជា៖ ស្ថិតិធុរកិច្ចអនុវត្តន៍**

**គម្រោងការស្រាវជ្រាវខ្នាតតូច (៣០ ពិន្ទុ)**

## សេចក្ដីណែនាំ

ក្រុមនីមួយៗ ត្រូវធ្វើការសិក្សាស្រាវជ្រាវខ្លីមួយ ស្ដីពី "**ទស្សនៈអ្នកប្រើប្រាស់បណ្ដាញសង្គមលើការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ធនាគារ**__________" ដោយប្រើប្រាស់កម្រងសំណួរដែលជាឧបសម្ព័ន្ធនៃសេចក្ដីណែនាំនេះជាគម្រូ។

ការសិក្សាស្រាវជ្រាវខ្លីនេះ ចែកចេញជា បី ដំណាក់កាល៖

**ដំណាក់កាលទី១. ការស្ទង់មតិ**
ក្រុមនីមួយៗ ត្រូវជ្រើសរើសធនាគារក្នុងស្រុកមួយជាអង្គភាពគោលដៅ និងសាកសួរអ្នកប្រើប្រាស់បណ្ដាញសង្គម ឱ្យបានយ៉ាងតិច ៥០ នាក់។ ក្រុមនីមួយៗ អាចប្រើប្រាស់មធ្យោបាយណាមួយក៏បាន។

**ដំណាក់កាលទី២. ការវិភាគទិន្នន័យ**
ក្នុងការវិភាគទិន្នន័យ, ក្រុមនីមួយៗ ត្រូវបំពេញកិច្ចការដូចខាងក្រោម៖

(១០ ពិន្ទុ) ក. ចូរសង្ខេបទិន្នន័យសម្រាប់សំណួរនីមួយៗ តាមរយៈតារាង ឬ/និង ក្រាប។ ក្នុងនោះ, ត្រូវមានអ៊ីស្តូក្រាម (Histogram) យ៉ាងហោចណាស់មួយ។ បន្ទាប់មកទៀត, សូមផ្ដល់ការពិពណ៌នា ឬ ការសន្និដ្ឋានដែលសមស្របសម្រាប់តារាង ឬ/និង ក្រាបនីមួយៗ។

(១៥ ពិន្ទុ) ខ. ចូរវិភាគ និងសន្និដ្ឋានពីទំនាក់ទំនងរវាង កម្រិតនៃការប្រើប្រាស់បណ្ដាញសង្គមក្នុងមួយថ្ងៃ (សំណួរ ២.១.) និង កម្រិតនៃការមើលឃើញប៉ុស្តិ៍ផ្សាយពាណិជ្ជកម្មរបស់ធនាគារនៅលើបណ្ដាញសង្គម (សំណួរ ២.២.) ដោយប្រើរង្វាស់ Correlation Coefficient តាមទ្រឹស្ដីលោក Edmund Robert Spearman (1863-1945)។ ទន្ទឹមនេះ, ពន្យល់ពីមូលហេតុដែលរង្វាស់ Correlation Coefficient តាមទ្រឹស្ដីលោក Karl Pearson (1857-1936) មិនសមស្របសម្រាប់កិច្ចការវិភាគនេះ។

(៥ ពិន្ទុ) គ. សន្មតថាអ្នកនឹងត្រូវប្រមូលទិន្នន័យបន្ថែម ដោយប្រើប្រាស់កម្រងសំណួរដដែល។ ចូរកំណត់ប្រភេទបំណែងចែកប្រូបាប៊ីលីតេរបស់អថេរ "កម្រិតនៃការផ្សាយពាណិជ្ជកម្មរបស់ធនាគារ" និង ពន្យល់ពីមូលហេតុនៃការសម្រេចចិត្តរបស់អ្នក។

**ដំណាក់កាលទី៣. ការសរសេររបាយការណ៍**
បន្ទាប់ពីបញ្ចប់ការវិភាគ ក្រុមនីមួយៗ ត្រូវរៀបចំរបាយការណ៍ខ្លីមួយ ជាភាសាខ្មែរ ដើម្បីបង្ហាញពីលទ្ធផលនៃការវិភាគខាងលើ។

**ឧបសម្ព័ន្ធ៖ គម្រូទសំណួរគម្រូ**

**ឧស្សនៈអ្នកប្រើប្រាស់បណ្ដាញសង្គមលើការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ធនាគារ ក**

**សូមជ្រើសរើសចម្លើយរបស់អ្នក សម្រាប់សំណួរនីមួយៗ ដូចខាងក្រោម៖**

**ផ្នែកទី១. ព័ត៌មានផ្ទាល់ខ្លួន**

១.១. ភេទ៖ ☐ប្រុស ☐ស្រី

១.២. អាយុ៖ ☐ ក្រោម ២០ ឆ្នាំ ☐ ២១ ឆ្នាំ ដល់ ២៥ ឆ្នាំ ☐ ២៦ ឆ្នាំ ដល់ ៣០ ឆ្នាំ

☐ ៣១ ឆ្នាំ ដល់ ៣៥ ឆ្នាំ ☐ លើស ៣៥ ឆ្នាំ

**ផ្នែកទី២. សំណួរអង្កេត**

២.១. តើអ្នកប្រើប្រាស់បណ្ដាញសង្គមញឹកញាប់កម្រិតណា ក្នុងមួយថ្ងៃ?

☐ ក្រោម ១ ម៉ោង ☐ ១ ដល់ ២ ម៉ោង ☐ ២ ដល់ ៣ ម៉ោង

☐ ៣ ដល់ ៤ ម៉ោង ☐ លើស ៥ ម៉ោង

២.២. តើក្នុងមួយថ្ងៃ អ្នកឃើញការផ្សាយពាណិជ្ជកម្មរបស់ធនាគារ ក ច្រើនកម្រិតណាដែរ នៅលើបណ្ដាញសង្គម?

☐ តិចតួចណាស់ ☐ តិចតួច ☐ មធ្យម

☐ ច្រើន ☐ ច្រើនណាស់

២.៣. តើអ្នកគិតថាធនាគារធនាគារ ក គួរបង្កើនការផ្សាយពាណិជ្ជកម្ម នៅលើបណ្ដាញសង្គមដែរឬទេ?

☐ គួរបង្កើន ☐ មិនគួរបង្កើនទេ

២.៤. តើអ្នកគិតថាការផ្សាយពាណិជ្ជកម្មរបស់ធនាគារធនាគារ ក ងាយយល់កម្រិតណា?

☐ ពិបាកយល់ ☐ មធ្យម ☐ ងាយយល់

២.៥. ក្នុងចំណោមសេវាកម្មទាំងអស់របស់ធនាគារ, តើអ្នកឃើញពីការផ្សព្វផ្សាយសេវាកម្មមួយណាញឹកញាប់ជាងគេ?

☐ សេវាឥណទាន ☐ សេវាប្រាក់បញ្ញើ ☐ សេវាចាត់ចែងសាច់ប្រាក់

☐ សេវាផ្ទេរប្រាក់ ☐ សេវាហិរញ្ញប្បទានពាណិជ្ជកម្ម ☐ សេវាពាក់ព័ន្ធនឹងមូលបត្រ

☐ សេវាពិនិត្យសុខភាពហិរញ្ញវត្ថុ ☐ សេវាឌីជីថល ☐ សេវាប័ណ្ណឥណទាន/ឥណពន្ធ

☐ ផ្សេងៗ

២.៦. តើអ្នកធ្លាប់សាកសួរពីសេវាកម្មផ្សេងៗ ទៅភ្នាក់ងារធនាគារធនាគារ ក តាមរយៈការផ្សាយពាណិជ្ជកម្មរបស់ធនាគារនៅលើបណ្ដាញសង្គមដែរឬទេ?

☐ ធ្លាប់ ☐ មិនធ្លាប់

២.៧. តើអ្នកគិតថា ការឆ្លើយតបរបស់ភ្នាក់ងារធនាគារ ក ល្អកម្រិតណាដែរ?

☐ ខ្សោយ ☐ មធ្យម ☐ ល្អ

២.៨. តើអ្នកគិតថា ការផ្សាយពាណិជ្ជកម្មរបស់ធនាគារ ក លើកទឹកចិត្តឱ្យអ្នកប្រើប្រាស់សេវាកម្មរបស់ធនាគារ ក ដែរឬទេ?

☐ បាទ/ចាស ☐ មិនមែនទេ

**បញ្ចប់កម្រងសំណួរ**